Reading Book

# ពិភពរឿងនិទាន
# The World of Stories

# រឿង យក្ខិនីមុខសេះ
## Horse Faced-Ogress



M.57

ថ្នាំញៀនធ្វើឱ្យមនុស្សខូចសុខភាព និងគ្រោះថ្នាក់ដល់ជីវិត



ក្នុងកាលកន្លងទៅយូរណាស់មកហើយ មានព្រះរាជាមួយព្រះអង្គសោយរាជ្យនៅក្រុងពារាណសី។ ទ្រង់មានព្រះអគ្គមហេសីដែលចូលចិត្តផឹកសុរា និយាយកុហក និងប្រព្រឹត្តតែអំពើក្បត់ចិត្តស្វាមី។

លុះព្រះនាងទទួលមរណភាពទៅក៏កើតជាយក្ខិនីខុសប្លែកអំពី ត្រកូលយក្សផ្សេងៗ គឺមានខ្លួនជាយក្ស មុខជាសេះឈ្មោះថា **អស្សមុខិយក្ខិនី** ស្ថិតនៅក្នុងលេណគុហានាបាតភ្នំមួយបានចូលទៅ បម្រើស្ដេចវេស្សវ័ណអស់វារៈបីឆ្នាំ។ ស្ដេចទ្រង់ប្រទានគោចរភក្ស មួយមានបណ្ដោយ៣០យោជន៍ ទទឹង៥យោជន៍ ដើម្បីចាប់មនុស្សសត្វបរិភោគ។





Long long ago, there reigned a king in Beranes City. He had a queen who was fond of drinking alcohol, telling a lie, and committed adulteries. Upon her death, her soul reincarnated as an ogress bizarre to those of other giant ethnics as she had a horse face. She was called Asmukhe Ogress, living in a cave in the bed of a mountain as a servant of King Vesvoan for three years. The King offered her limited boundary of 30 yauches (one yauch equals to around 16 kilometers) in length and 5 yauches in width, within which she could travel to hunt for humans and animals as food.



ថ្ងៃមួយយក្ខិនីមុខសេះនោះ ចាប់បានព្រាហ្មណ៍កំលោះម្នាក់មានរូបឆោមល្អសមរម្យក៏នាំយកទៅទុកក្នុងគុហាដើម្បីធ្វើជាស្វាមី។ ចាប់តាំងពីថ្ងៃនោះមក យក្ខិនីខំស្វះស្វែងរកចាប់មនុស្សដើម្បីយកវត្ថុផ្សេងៗមានសំពត់អាវ អង្ករ ត្រីសាច់ ម្ហូបចំណីដែលមានឱជារសទៅចិញ្ចឹមព្រាហ្មជាស្វាមីនោះរាល់ថ្ងៃ។

One day, the horse faced-ogress caught a single handsome Brahman, and she kept him in a large cave to serve as her husband. The ogress had ever since tried her best to hunt for humans and took possessions of their belongings, including cloth, shirt, rice, fish, meat and other kinds of foods to feed her husband, the Brahman.





រាល់ពេលដែលយក្ខិនីចេញទៅរកអាហារ នាងបានយកដុំថ្មមួយដុំធំមកខ្ទប់មាត់ទ្វារ ព្រោះខ្លាចព្រាហ្មណ៍នោះរត់ចោល។ ក្នុងគ្រានោះ ព្រះពោធិសត្វបានមកចាប់បដិសន្ធិក្នុងផ្ទៃរបស់នាង។ លុះគ្រប់ទសមាស នាងប្រសូតបានកូនប្រុសម្នាក់មានរូបរាងល្អប្រិមប្រិយគួរឱ្យស្រឡាញ់។ នាងយក្ខិនីមុខសេះមានសេចក្ដីស្រឡាញ់ចំពោះកូននិងប្ដីយ៉ាងក្រៃលែង នាងតែងតែទំនុកបំរុងដោយភោជនាហារជាទីគាប់ចិត្ត។

Every time she went out to hunt for food, she had always blocked the gateway of the cave with a large rock, for she was afraid that the Brahman ran away. During the time, Buddha reincarnated as a fetus in her womb. Upon maturity of ten months, she gave birth to a lovely boy. The horse faced-ogress loved her son and husband very dearly, and she always provide them with their favorite food.

លុះព្រះពោធិសត្វមានវ័យធំឡើង ក៏ប្រមៀលដុំថ្មដែលម្ដាយខ្ទប់ទ្វារនោះចេញ ហើយនាំឱពុកមកអង្គុយលេងនៅខាងក្រៅ។ ដល់ពេលយក្ខិនីត្រឡប់មកវិញ កូនបានប្រាប់ម្ដាយភ្លាមថា "កូនបានប្រមៀលដុំថ្មនេះចេញហើយ ព្រោះនៅខាងក្នុងងងឹតហើយអផ្សុកខ្លាំងណាស់"។ ហេតុតែយក្ខិនីស្រឡាញ់កូនក៏នៅស្ងៀមមិនស្ដីថាអ្វីឱ្យកូនឡើយ។



Growing adult, Buddha pushed out the rock blocking the cave gateway, and brought his dad out of the cave to have a sit nearby. Seeing his mother return, Buddha told his mother immediately, 'I pushed the stone out as I found very dark and lonely inside.' With the deep love for her son, the ogress was calm, not saying any words of blame to her son.





ថ្ងៃក្រោយមកទៀត ព្រះពោធិសត្វមានសេចក្ដីងឿងឆ្ងល់នឹងម្ដាយរបស់ខ្លួនណាស់ ថាហេតុអ្វីបានជាម្ដាយមានមុខដូចសេះ ទើបសួរទៅឪពុកៗប្រាប់កូនថា "កូនមាសឪពុក ម្ដាយឯងជាយក្សទេ យើងទាំងពីរនាក់ទើបជាមនុស្ស។



បន្ទាប់ពីព្រះពោធិសត្វបានដឹងហេតុសព្វគ្រប់ហើយ  ក៏នាំឪពុករត់ចេញពីទីនោះទៅ។

Curious of why his mother had a horse face, he asked his dad for the reason, and his dad replied, 'My dear son! Your mother is an ogress; we both are human beings.' Being informed of the facts, he brought his dad away from the cave.



យក្ខិនីត្រឡប់មកវិញមិនឃើញប្ដីនិងកូន ក៏ហោះទៅតាមមានសន្ទុះលឿនដូចខ្យល់ ក៏ទៅទាន់ពួកគេនៅពាក់កណ្ដាលផ្លូវ ហើយនាំក្រុមគ្រួសារមកគុហាវិញ។ ក្រោយមកកូននោះបាននាំឪពុករត់ម្ដងទៀត យក្ខិនីក៏តាមទាន់ទៀត។ ថ្ងៃមួយព្រះពោធិសត្វបានគិតថា "មាតារបស់អញ មានទឹកដីជាទីស្ថានបរិច្ឆេទកំណត់ពីត្រឹមណាដល់ត្រឹមណា?" លុះគិតដូច្នេះហើយក៏សួរទៅម្ដាយៗបានប្រាប់ទីស្ថានខេត្តរបស់ខ្លួនសព្វគ្រប់ដល់កូន។

The ogress returned and could not find her husband and son. She flew in a windy speed and saw them on the way. Then she got them back to the cave. Later, the son tried to get his father away again, but he failed as the ogress arrived. One day, the Buddha understood that his mother had alimited authorized boundary where she could travel. With this knowledge, he asked his mother who then told him such limited authorized boundary.



ថ្ងៃមួយព្រះពោធិសត្វបានឱកាសល្អ ក៏បញ្ចិះឪពុករត់ចេញយ៉ាងលឿន ហើយក៏បានទៅដល់មាត់ស្ទឹងជាព្រំដែនរបស់យក្ខិនីនោះ ក៏ប្រញាប់នាំឪពុកឆ្លងស្ទឹងនោះទៅ។ លុះដល់ពាក់កណ្ដាលស្ទឹង យក្ខិនីតាមមកទាន់ ប៉ុន្តែពុំអាចចាប់យកប្ដីនិងកូនមកវិញបានឡើយ ព្រោះហួសព្រំដែនរបស់ខ្លួន នាងក៏ខំនិយាយអង្វរកូននិងប្ដីនោះឱ្យត្រឡប់មកវិញដោយប្រការផ្សេងៗ។



One day, under a good circumstance, Buddha got his father to flee the cave in a rushed speed to a stream that was the ogress's limited boundary, and they hurried to pass the stream. Arriving at the middle of the stream, the ogress arrived, but she could not catch her husband and son as they were out of her authorized boundary. She tried to implore her son and husband to come back for a variety of reasons.

យក្ខិនីដឹងថា ជនទាំងពីរនាក់មិនត្រឡប់មកវិញ ក៏មានសេចក្ដីខ្សឹកខ្សួលយំសោកបោកខ្លួន ព្រោះតែស្រឡាញ់កូននិងប្ដី ទើបនិយាយនឹងកូនថា



"កូនសម្លាញ់មាសម្ដាយ បើកូនមិនត្រឡប់មកវិញទេ ចូរកូនរៀនយកមន្តវិជ្ជាឈ្មោះចិន្តាមណីពីម្ដាយចុះ ព្រោះមនុស្សលោក បើគ្មានសិប្បៈហើយ រស់នៅដោយកម្រពេកណាស់ ឯមន្តវិជ្ជាឈ្មោះចិន្តាមណីនេះមានតម្លៃខ្ពង់ខ្ពស់ ព្រោះមានអានុភាពយ៉ាងវិសេស។

Knowing that they both would not return, she started to weep because of her deep love for her son and husband. She screamed, 'Oh my beloved son! If you decided not to return, please learn the incantation called chenda moni from me, because people living without this incantation, which is very worthy and powerful, would face difficulty.'



ព្រះពោធិសត្វឈរនៅពាក់កណ្តាលស្ទឹង បានស្តាប់ម្តាយថ្លែងគុណវិសេសនៃមន្តវិជ្ជាឈ្មោះចិន្តាមណីនោះរួចហើយ ក៏ថ្វាយបង្គំម្តាយរៀនយកនូវមន្តវិជ្ជាដោយសព្វគ្រប់ ហើយស្រែកលាម្តាយ "សូមអ្នកម្តាយត្រឡប់ទៅវិញចុះ កូនសូមថ្វាយបង្គំលាសិនហើយ"។

Standing in the middle of the stream, Buddha listened to incantation of chenda moni from his mother. After completion of the learning, he saluted and said farewell to his mother that 'Please, go back mum! May I say a good bye to you.'



ចំណែកនាងយក្ខិនីក៏ប្រហារដើមទ្រូងស្លាប់ក្នុងពេលនោះទៅ។ ព្រះពោធិសត្វឃើញម្ដាយស្លាប់ក៏យំសោកសង្រេងក្រៃលែង ហើយនាំឪពុកចាត់ចែងធ្វើពិធីតំកល់សព។ លុះបូជារួចហើយក៏បេះផ្កាវុក្ខជាតិផ្សេងៗយកទៅបូជាធាតុម្ដាយ។ ឯឪពុកក៏ទៅសាងផ្នោះបួសជាតាបស។ ចំណែកកូនក៏លាឪពុកទៅកាន់ក្រុងពារាណសីទៅ។

**រូបអាក្រក់ ប្រសើរជាងចិត្តអាក្រក់**



The ogress then stabbed her chest to death. Seeing his mother dying, Buddha cried sorrowfully, and led his father to organize a funeral for his mother. Upon the body was cremated, he picked some flowers from small plants nearby to dedicate ashes of his mother. His father subsequently served his life as a hermit, whereas the son said farewell to his dad and left for Beranes City. **The End!**

## UGLY IS BETTER THAN EVIL-MINDED